# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**
លេខ...០៦៥.....ន.គ.ស/សស.ណា.ន.

ថ្ងៃចន្ទ ១០កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែកញ្ញា ឆ្នាំ២០២២

# សេចក្តីណែនាំ
## ស្តីពី
## សំណុំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ ដែលមិនជាប់កាតព្វកិច្ចរងសវនកម្មឯករាជ្យ

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម អនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ប្រកាសលេខ៥៦៣ សហវ.ប្រក. ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០ ស្តីពីកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ និងសេចក្តីណែនាំលេខ០១០ ន.គ.ស ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ ស្តីពីការអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្ម សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ ដែលហៅកាត់ថា "អង្គភាព" **និយ័តករគណនេយ្យនិងសវនកម្ម (ន.គ.ស.)** សូមធ្វើការណែនាំអំពីសំណុំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែល អង្គភាព ត្រូវដាក់បញ្ជូនតាមប្រព័ន្ធអនឡាញ (E-Filing for NFPEs) មក **ន.គ.ស.** មានដូចខាងក្រោម÷

១.របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ឬរបាយការណ៍របស់ប្រធានអង្គភាព

២. សំណុំរបាយការណ៍ហិរញ្ញវត្ថុពេញលេញ ស្របតាមស្តង់ដាគណនេយ្យជាធរមាន

ដើម្បីផ្តល់ភាពងាយស្រួលដល់ អង្គភាព ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ **ន.គ.ស.** សូមផ្តល់គំរូរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល ឬរបាយការណ៍របស់ប្រធានអង្គភាព ដូចមានក្នុងឧបសម្ព័ន្ធនៃសេចក្តីណែនាំនេះ។

**និយ័តករគណនេយ្យនិងសវនកម្ម** សង្ឃឹមយ៉ាងមុតមាំថា អង្គភាពទាំងអស់នឹងយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះ ឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ដើម្បីទទួលបានបច្ចុប្បន្នភាពព័ត៌មានអំពីវិស័យនិងវិជ្ជាជីវៈគណនេយ្យ
និងសវនកម្ម សូមចូលរួមក្នុងTelegram Channel របស់
**និយ័តករគណនេយ្យនិងសវនកម្ម**

**អគ្គនាយក**

**ប៊ូ ថារិន**

| ឈ្មោះ និង និមិត្តសញ្ញាអង្គភាព | សម្រាប់អង្គភាពមានក្រុមប្រឹក្សាភិបាល |
|---|---|

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលសូមដាក់ជូននូវរបាយការណ៍ក្រុមប្រឹក្សាភិបាលព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុរបស់ **[ឈ្មោះអង្គភាពមិនស្វែងរកប្រាក់ចំណេញ]** ហៅកាត់ថា "**អង្គភាព**" សម្រាប់កាលបរិច្ឆេទគិតត្រឹម**ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ២០២១។**

### អង្គភាព

**អង្គភាព [ឈ្មោះអង្គភាព]** បានបង្កើតក្នុងប្រទេសកម្ពុជា ជា **[អង្គការ -សមាគម]** ដែលបានចុះបញ្ជីលេខ [111111111] នៅថ្ងៃទី... ខែ ......... ឆ្នាំ ......... ចេញដោយក្រសួង-ស្ថាប័ន ....... នៃព្រះរាជាណាចក្រកម្ពុជា។

### សកម្មភាពចម្បងអង្គភាព

សកម្មភាពចម្បងរបស់**[អង្គភាព]** គឺ [.........។ **អង្គភាព** ពុំមានការផ្លាស់ប្ដូរជាសារវន្តសម្រាប់សកម្មភាពចម្បងរបស់ខ្លួនក្នុងការិយបរិច្ឆេទនេះទេ។

### លទ្ធផលនៃប្រតិបត្តិការហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទបានបញ្ចប់ថ្ងៃ**ទី៣១ ខែ ធ្នូ ឆ្នាំ ២០២១** ត្រូវបានកំណត់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានបង្ហាញខាងក្រោមនេះ។

### ក្រុមប្រឹក្សាភិបាល

សមាសភាពក្រុមប្រឹក្សាភិបាល ដែលបានបម្រើការនៅក្នុងការិយបរិច្ឆេទនៃរបាយការណ៍នេះ រួមមាន÷

| **ឈ្មោះ** | **តួនាទី** |
|---|---|
| ១. លោក......... | ប្រធានក្រុមប្រឹក្សាភិបាល |
| ២. លោកស្រី...... | សមាជិកក្រុមប្រឹក្សាភិបាល |

### ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារកិច្ចបញ្ជាក់អះអាងថា របាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំឡើងបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវពីស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាព សម្រាប់ការិយបរិច្ឆេទគិតត្រឹម**ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ២០២១** ព្រមទាំងលទ្ធផលនៃសកម្មភាពប្រតិបត្តិការ និងស្ថានភាពលំហូរសាច់ប្រាក់របស់អង្គភាព សម្រាប់ការិយបរិច្ឆេទនេះ។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលត្រូវបានតម្រូវឱ្យ÷

ក. អនុម័តគោលនយោបាយគណនេយ្យស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ CFRS for NFPEs **[ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម "CIFRS for SMEs" ]** / **[ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា**

"CIFRS"] ដែលគាំទ្រដោយការវិនិច្ឆ័យនិងការប៉ាន់ស្មានសមហេតុផល និងប្រុងប្រយ័ត្ន ហើយបន្ទាប់មកធ្វើការអនុវត្តគោលការណ៍ទាំងនេះឱ្យបានជាប់ជាប្រចាំ។

ខ. អនុលោមតាមគោលការណ៍ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា[ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា "CIFRS"] ហើយប្រសិនបើមានការប្រាសចាកណាមួយពីស្តង់ដាទាំងនោះក្នុងការបង្ហាញពីទិដ្ឋភាពពិតនិងត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថា ការប្រាសចាកទាំងនេះត្រូវបានលាតត្រដាងពន្យល់ និង កំណត់បរិមាណឱ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍។

គ. រក្សាកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព។

ឃ. រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋានគោលការណ៍និរន្តភាពនៃដំណើរការសកម្មភាពលើកលែងតែក្នុងករណីមិនអាចសន្មតសមស្របថា អង្គភាពនឹងបន្តធ្វើសកម្មភាពប្រតិបត្តិការរបស់ខ្លួននាពេលអនាគត និង

ង. ត្រួតពិនិត្យ និងដឹកនាំអង្គភាពឱ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេចចិត្តសំខាន់ៗដែលប៉ះពាល់ដល់ប្រតិបត្តិការនិងដំណើរការអង្គភាព ហើយត្រូវប្រាកដថាកិច្ចការទាំងនេះត្រូវបានបង្ហាញត្រឹមត្រូវនៅក្នុងរបាយការណ៍-ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលអះអាងថា អង្គភាពបានអនុវត្តតាមរាល់លក្ខខណ្ឌតម្រូវខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

**សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល**

ក្នុងនាមជាក្រុមប្រឹក្សាភិបាល យើងខ្ញុំសូមបញ្ជាក់អះអាងថារបាយការណ៍ហិរញ្ញវត្ថុបង្ហាញទិដ្ឋភាពពិត និងត្រឹមត្រូវពីស្ថានភាពហិរញ្ញវត្ថុរបស់ **អង្គភាព** សម្រាប់ការិយបរិច្ឆេទគណនេយ្យគិតត្រឹមថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ២០២១ ព្រមទាំងលទ្ធផលនៃសកម្មភាពប្រតិបត្តិការ និងស្ថានភាពលំហូរសាច់ប្រាក់របស់ **អង្គភាព** សម្រាប់ការិយបរិច្ឆេទនេះដោយអនុលោមតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ CNPEs ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម (CIFRS for SMEs) [ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា "CIFRS"]។

ថ្ងៃ ខែ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ២០២២

**តំណាងឱ្យក្រុមប្រឹក្សាភិបាល**

---

[**ឈ្មោះ**..........................]

តួនាទី

| ឈ្មោះ និង និមិត្តសញ្ញាអង្គភាព | សម្រាប់អង្គភាព ពុំមានក្រុមប្រឹក្សាភិបាល |
|---|---|

## របាយការណ៍របស់ប្រធានអង្គភាព

ខ្ញុំសូមដាក់ជូននូវរបាយការណ៍របស់អង្គភាព ព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុរបស់ **[ឈ្មោះអង្គភាពមិនស្វែងរកប្រាក់ចំណេញ]** ហៅកាត់ថា "**អង្គភាព**" សម្រាប់កាលបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ២០២១។

## អង្គភាព

**អង្គភាព [ឈ្មោះ]** បានបង្កើតក្នុងប្រទេសកម្ពុជា ជា **[អង្គការ -សមាគម]** ដែលបានចុះបញ្ជីលេខ [11111111] នៅថ្ងៃទី... ខែ .......... ឆ្នាំ .......... ចេញដោយក្រសួង ស្ថាប័ន ឈ្មោះស្ថាប័ន នៃព្រះរាជាណាចក្រកម្ពុជា។

## សកម្មភាពចម្បង

សកម្មភាពចម្បងរបស់អង្គភាព គឺ [..........]។ អង្គភាពពុំមានការផ្លាស់ប្តូរជាសារវ័ន្តសម្រាប់សកម្មភាពចម្បងរបស់ខ្លួនក្នុងការិយបរិច្ឆេទនេះទេ។

## លទ្ធផលនៃប្រតិបត្តិការហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទបានបញ្ចប់ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ២០២១ ត្រូវបានកំណត់នៅក្នុងរបាយ-ការណ៍ហិរញ្ញវត្ថុដែលត្រូវបានបង្ហាញខាងក្រោមនេះ។

## ប្រធានអង្គភាព

| **ឈ្មោះ** | **តួនាទី** |
|---|---|
| លោក......... | ជានាយក និងជាអ្នកគ្រប់គ្រងទូទៅ |

## ការទទួលខុសត្រូវរបស់ប្រធានអង្គភាពក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ប្រធានអង្គភាពមានភារកិច្ចបញ្ជាក់អះអាងថារបាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំឡើងបានបង្ហាញទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាព សម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ២០២១ ព្រមទាំងលទ្ធផលនៃសកម្មភាពប្រតិបត្តិការ និងស្ថានភាពលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទនេះ។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ប្រធានអង្គភាពត្រូវបានតម្រូវឱ្យ÷

ក. អនុម័តគោលនយោបាយគណនេយ្យស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ “CFRS for NFPEs” ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម “CIFRS for SMEs” / [ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា

"CIFRS"] ដែលគាំទ្រដោយការវិនិច្ឆ័យនិងការប៉ាន់ស្មានសមហេតុផល និងប្រុងប្រយ័ត្ន ហើយបន្ទាប់មកធ្វើការអនុវត្តគោលការណ៍ទាំងនេះឱ្យបានជាប់ជាប្រចាំ។

ខ. អនុលោមតាមគោលការណ៍ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា[ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា "CIFRS"] ហើយប្រសិនបើមានការប្រាសចាកណាមួយពីស្តង់ដាទាំងនោះក្នុងការបង្ហាញនូវទិដ្ឋភាពពិតនិងត្រឹមត្រូវ ម្ចាស់សហគ្រាសត្រូវប្រាកដថា ការប្រាសចាកទាំងនេះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណឱ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍។

គ. រក្សាកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព។

ឃ. រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋានគោលការណ៍និរន្តភាពនៃដំណើរការសកម្មភាព លើកលែងតែក្នុងករណីមិនអាចសន្មតសមស្របថា អង្គភាពនឹងបន្តធ្វើសកម្មភាពប្រតិបត្តិការ របស់ខ្លួននាពេលអនាគត និង

ង. ត្រួតពិនិត្យ និងដឹកនាំអង្គភាពឱ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេចចិត្តសំខាន់ៗដែលប៉ះពាល់ដល់ប្រតិបត្តិការនិងដំណើរការអង្គភាព ហើយត្រូវប្រាកដថាកិច្ចការទាំងនេះត្រូវបានបង្ហាញត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ខ្ញុំអះអាងថា អង្គភាពបានអនុវត្តតាមរាល់លក្ខខណ្ឌតម្រូវខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## សេចក្តីថ្លែងការណ៍របស់ប្រធានអង្គភាព

ក្នុងនាមជាប្រធានអង្គភាព យើងខ្ញុំសូមបញ្ជាក់អះអាងថារបាយការណ៍ហិរញ្ញវត្ថុបង្ហាញទិដ្ឋភាពពិត និងត្រឹមត្រូវពីស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាព សម្រាប់ការិយបរិច្ឆេទគណនេយ្យគិតត្រឹមថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ២០២១ ព្រមទាំងលទ្ធផលនៃសកម្មភាពប្រតិបត្តិការ និងស្ថានភាពលំហូរសាច់ប្រាក់របស់អង្គភាពសម្រាប់ការិយបរិច្ឆេទនេះ ដោយអនុលោមតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ CNPEs ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម( CIFRS for SMEs) [ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា "CIFRS"]។

ថ្ងៃ ខែ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ២០២២

**ប្រធានអង្គភាព**

---

[ឈ្មោះ.........................]